# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៣-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៤៩ ស្តីពីការប្រោសព្រះរាជទានគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំនួន ០៧ រូប ៧៤៩០

១៣-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៥០ ស្តីពីការផ្លាស់ឯកឧត្តម **ខៀវ ឡឹមចំ** បច្ចុប្បន្ន ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណ រដ្ឋប្រជាមានិតចិន វិលចូលប្រទេសវិញ ៧៤៩១

១៣-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៥១ ស្តីពីការតែងតាំងលោកជំទាវ **ខៀវ កែមាលី ស៊ីសូដា** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំ សាធារណ រដ្ឋប្រជាមានិតចិន ៧៤៩២


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២១-១១-២០០៦ -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៤៩៣

២១-១១-២០០៦ -អនុក្រឹត្យលេខ ៧១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៤៩៥

២១-១១-២០០៦ -អនុក្រឹត្យលេខ ៧២០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៤៩៦

២១-១១-២០០៦ -អនុក្រឹត្យលេខ ៧២១ អនក្រ.តត ស្តីពីការសំរួល និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៤៩៨

២១-១១-២០០៦ -អនុក្រឹត្យលេខ ៧២២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៥០០

២១-១១-២០០៦ -អនុក្រឹត្យលេខ ៧២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៥០១


### ២-បទបញ្ជា


១៥-១១-២០០៦ -បទបញ្ជាលេខ ០៥ បប ស្តីពីវិធានការការពារ និង អភិរក្សដើមត្នោត ៧៥០២


## III-ការិយាល័យក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៧-១១-២០០៦ -ប្រកាសលេខ ១១៧៨ សហវ ស្តីពីការបង្កើតក្រុមការងារ សម្រាប់កិច្ចប្រជុំ «ច្រកចេញ-ចូលតែមួយ» និង កិច្ចប្រជុំយន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៧៥០៥

២១-១១-២០០៦ -ប្រកាសអន្តរក្រសួងលេខ ១១៩១ សហវ.ប្រក.ចមព ស្តីពីការអាករប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ៧៥០៨

១៧-១១-២០០៦ -សេចក្តីណែនាំលេខ ០០៧ សហវ ស្តីពីការចូលរួមប្រជុំ «ច្រកចេញ-ចូលតែមួយ» និងយន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ៧៥១២

## ២-ឯកសារក្រសួងព័ត៌មាន

២១-១១-២០០៦ -ប្រកាសលេខ ៣៩៣/០៦ ពម.ប្រក ស្តីពីការបង្កើតការិយាល័យព័ត៌មានវិទ្យា ៧៥១៤

## ៣-ឯកសារក្រសួងធនធានទឹក និង ឧតុនិយម

១៧-១១-២០០៦ -ប្រកាសលេខ ១៨២ប្រក.ធទឧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងធនធានទឹក និងឧតុនិយម ៧៥១៧

## ៤-ឯកសារក្រសួងពាណិជ្ជកម្ម

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៧៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ុយ៉ុន ជុង** ៧៥២៣

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៧៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ-វីណា** ៧៥២៥

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៨៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃាការ ខេមីរេង & ហ្វ៊ីស៊ុឡឺធី មេនេចមេន** ៧៥២៧

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៨៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ម៉ែនញូម៉ិន** ៧៥២៩

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៨៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមខូសម៉ូ** ៧៥៣១

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៩០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃាង តៃខិន** ៧៥៣៣

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៩១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម.ស៊ី.ឌី. ត្រេឌីង** ៧៥៣៥

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៩៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វើលវ៉ាយដ៍ មូវើរ អិចប្រេស** ៧៥៣៧

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៩៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីឡាម៉ា ១៨ ខមភេនី** ៧៥៣៩

២៩-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៥០០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សំណាង លាភ ត្រេឌីង លីមីធីត** ៧៥៤០

នស/រកត/១១០៦/៤៤៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

## ប្រោសព្រះរាជទាន

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :**

១-ឧកញ៉ា ខេង សុមេធ
២-លោក ឆូច សឿ
៣-លោក ស៊ីន គង់
៤-លោក ខាត់ តាំងសួគី
៥-លោក ជា រ៉ាវី
៦-លោក យិន ឌី
៧-លោក ស្រេង អូន

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៦១១.៤៧៥

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦

លេខ : ៤៤៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្លាស់ឯកឧត្តម ខៃក ឡឺរ៉ង់ បច្ចុប្បន្នជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន វិលចូលប្រទេសវិញ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៦១១.៤៧៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០៦*

លេខ : ៤៧៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៥១

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងលោកជំទាវទេសរដ្ឋមន្ត្រី ខែក កែមាលី ស៊ីសូដា ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

ចរកល.០៦១១.៤៧៧

លេខ : ៤៨៤ច.ល

**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.៩៤០ លានរៀល ( មួយពាន់ប្រាំរយសែសិបលានរៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) ជូនក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយរបបជីវភាពទណ្ឌិតនិងពិរុទ្ធជន សំរាប់បួនខែចុងឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី៧១ ខែវិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ ✓

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៣៧១.៨..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប ជាជំនួយការ ឯកឧត្តម លី ធុច ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានទី ២ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចមានរាយនាមខាងក្រោម :

១- លោក ចៅ ឡាយ មានឋានៈស្មើ អគ្គនាយករង

២- លោកស្រី ស៊ុយ វិណោ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧២០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ខិន សារិន** ឋានន្តរស័ក្តិ ឧត្តមអភិបាល ថ្នាក់លេខ ៣ ក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ជាអភិបាលរងក្រុងព្រះសីហនុ ។

**មាត្រា ២ :** ឯកឧត្តម **ខិន សារិន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ៤ [illegible] ឆ្នាំ២០០៦

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (<u>ដើម្បីជូនជ្រាប</u>)
- ដូចមាត្រា ៤ (<u>ដើម្បីអនុវត្ត</u>)
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការសំរួល និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និង ថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចលោក **អ៊ុក ម៉ុណ្ណា** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១០ ពីអភិបាលស្រុករំដួល ខេត្តស្វាយរៀង ឱ្យមកបំរើការងារនៅសាលាខេត្តស្វាយរៀង ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល ។

**មាត្រា ២ :** ប្រគល់ភារកិច្ចជូនលោក **សូ ស៊ីតឿន** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ២ ជាអភិបាលស្រុករំដួល ខេត្តស្វាយរៀង ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល។

**មាត្រា ៣ :** លោក **សូ ស៊ីគៀន** ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២១០/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និង សាមីជន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ* ✓

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោកស្រី **ចាន់ មុនី** ជំនួយការកិច្ចការ POW/MIA ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនគណៈកម្មការ POW/MIA កម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកវរសេនីយ៍ឯក **ពេជ្រ ចន្ទ្ធា** សប្បុរសជននៅខេត្តបាត់ដំបង ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីជួយកសាងរបងសាលាបឋមសិក្សា ម៉ឺនជ័យ ខ្លោងទ្វារវត្តជ័យមុន្នី រូបសេះឈរ ចំនួន០២ ប៉ុស្តិ៍នគរបាលឃុំម៉ឺនជ័យ និងអណ្តូងស្នប់ ចំនួន១៥ ស្ថិតនៅក្នុងឃុំម៉ឺនជ័យ ស្រុករំដួល ខេត្តស្វាយរៀង ចំណាយអស់ថវិកា សរុបចំនួន ១៣.០៩១ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...០៥...បប..

# បទបញ្ជា
## ស្តីពី
## វិធានការការពារ និង អភិរក្សដើមត្នោត

ដើមត្នោត គឺជាប្រភេទរុក្ខជាតិដែលមានសារប្រយោជន៍ពិសេសច្រើនយ៉ាង និង មានចំនួនច្រើនសន្ធឹកសន្ធាប់ ព្រមទាំងបានផ្សារភ្ជាប់ជាមួយប្រវត្តិសាស្ត្រ និង វប្បធម៌ដ៏យូរលង់នៃព្រះរាជាណាចក្រកម្ពុជាយើង។ ប្រជាជនខ្មែរទាំងអស់គ្នាមានមោទនភាព និង កិត្យានុភាពយ៉ាងក្រៃលែង ដោយសារបុព្វបុរសយើងជាច្រើនជំនាន់កន្លងមក បានខិតខំព្យាយាមដាំដុះ ថែរក្សា និង ការពារប្រភេទរុក្ខជាតិត្នោតរហូតបានបន្សល់ទុកជាកេរដំណែលនៅពាសពេញផ្ទៃប្រទេសដ៏មានតម្លៃខាងសេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ និង បរិស្ថានឱ្យដល់ជំនាន់យើងបច្ចុប្បន្ននេះ។ អាស្រ័យហេតុនេះហើយ ទើបរាជរដ្ឋាភិបាលសម្រេចចាត់បញ្ចូលដើមត្នោតជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិតាមរយៈព្រះរាជក្រឹត្យ លេខ.នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៥ ស្តីពីការកំណត់ ប្រភេទសត្វ និង រុក្ខជាតិសម្រាប់និមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងរក្សានូវកេរដំណែលនៃមរតកធម្មជាតិនេះឱ្យបានគង់វង្សជានិរន្តរ៍។

កន្លងមករាជរដ្ឋាភិបាល ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាស្ថាប័នមានសមត្ថកិច្ច បានយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារ និង ទប់ស្កាត់ការធ្វើអាជីវកម្មដើមត្នោតដោយអនាធិបតេយ្យដោយបានដាក់ចេញនូវវិធានការនានាក៏ដូចជាសារាចរណែនាំស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និង ការធ្វើ អាជីវកម្ម ការកែច្នៃ ដើមត្នោតក្នុងគោលបំណងការពារ ថែរក្សា និង អភិរក្សដើមត្នោត ដែលជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិនេះ។ ទោះជាមានវិធានការអនុវត្តហើយក្តី រាជរដ្ឋាភិបាលនៅតែសង្កេតឃើញមានសកម្មភាពនៃការកាប់រំលំដើមត្នោតជាលក្ខណៈប្រមូលផ្តុំសម្រាប់ធ្វើពាណិជ្ជកម្ម ដោយសារតែមានឈ្មួញកណ្តាលជាអ្នកបំផុសឱ្យកាប់ និង ដើរប្រមូលទិញ ធ្វើអាជីវកម្មដឹកជញ្ជូន កែច្នៃ នាំចេញទៅក្រៅប្រទេស ដែលធ្វើឱ្យសកម្មភាពកាន់តែរីករាលដាល ច្រើនឡើងៗពីតំបន់មួយទៅតំបន់មួយទៀតជាបន្តបន្ទាប់ និង បង្កនូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់រុក្ខជាតិប្រភេទនេះ។ ម្យ៉ាងវិញទៀត ប្រជាកសិករខ្លះយល់ឃើញថាដើមត្នោតបានដុះក្នុងបរិវេណដីកម្មសិទ្ធិ

របស់គាត់ គាត់មានសិទ្ធិប្រើប្រាស់ និង លក់ដូរទៅតាមតម្រូវការ ដោយមិនបានពិចារណាថា ដើមត្នោតជារុក្ខជាតិដែលផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាង យូរអង្វែង សម្រាប់ជីវភាពរស់នៅរបស់គាត់ ជារុក្ខជាតិតំណាងឱ្យនិមិត្តរូបជាតិ និង តំណាងឱ្យវប្បធម៌ខ្មែរដូចដែលមានចម្លាក់នៅលើជញ្ជាំងអង្គរវត្តជាសក្ខីភាពស្រាប់ និង មិនដែលនឹកស្មានថា កេរមរតកធម្មជាតិនេះ អាចឈានទៅរកការផុតពូជពីទឹកដីយើង ក៏ដូចជាធ្វើឱ្យបាត់បង់អត្តសញ្ញាណវប្បធម៌ អរិយធម៌ និង ប្រវត្តិសាស្ត្រធម្មជាតិរបស់ជាតិឡើយ។

ស្ថិតនៅក្នុងស្ថានភាពចំពោះមុខនេះ ដើម្បីធានាបាននូវការគ្រប់គ្រង និង ការប្រើប្រាស់ដើមត្នោតប្រកបដោយនិរន្តរភាព ទោះជាក្នុងរូបភាពឯកជន គ្រួសារ សមូហភាព ឬ សាធារណៈក្តី និង ដើម្បីរក្សាបាននូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច បរិស្ថាន និង វប្បធម៌របស់ប្រទេសជាតិ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវបទបញ្ជាដូចខាងក្រោម :

១-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីគ្រប់គ្រងសកម្មភាពទូទៅ ក្នុងការការពារ អភិរក្ស ដាំដុះ ប្រើប្រាស់ដើមត្នោតឱ្យមាននិរន្តរភាព។

២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបន្តផ្សព្វផ្សាយពីសារៈប្រយោជន៍របស់ដើមត្នោត និង ផលវិបាកនៃការបាត់បង់ដើមត្នោតជូនប្រជាពលរដ្ឋឱ្យបានយល់ជ្រួតជ្រាប។ លើសពីនេះទៅទៀត ត្រូវបន្តណែនាំឱ្យប្រជាពលរដ្ឋបានយល់ដឹង និង ចេះប្រើប្រាស់ដើមត្នោតឱ្យអស់លទ្ធភាព និង គប្បីកាប់តែដើមត្នោតណាដែលលែងផ្តល់ផល។

៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបំផុសចលនាដល់ប្រជាពលរដ្ឋឱ្យចូលរួមដាំដើមត្នោតនៅក្នុងមូលដ្ឋាន ជាពិសេសនៅរាល់ពិធីរុក្ខទិវា "៩ កក្កដា" ដើម្បីជំនួសដើមត្នោតដែលកាប់យកមកប្រើប្រាស់ផង និង ធានាបាននូវនិរន្តរភាពដើមត្នោតឱ្យនៅរាយប៉ាយពាសពេញផ្ទៃប្រទេសកម្ពុជាយើងផង។ បណ្តាខេត្តដែលគ្មានព្រៃឈើ និង តំបន់ជាប់ព្រំដែនត្រូវជំរុញចលនាដាំដើមត្នោត ដើម្បីរក្សាអនាគតមរតកធម្មជាតិនេះឱ្យបានគង់វង្ស។

៤-អាជ្ញាធរមូលដ្ឋាន ត្រូវសហការជាមួយសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការចុះស្រង់ស្ថិតិដើមត្នោតរបស់ប្រជាកសិករនៅគ្រប់មូលដ្ឋាន។

៥-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការជាមួយសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចាត់វិធានការទប់ស្កាត់ជាបន្ទាន់ រាល់សកម្មភាពកាប់រំលំជាលក្ខណៈប្រមូលផ្តុំ ដែលនាំមកនូវវិនាសកម្មដល់ដើមត្នោត។

៦-ប្រជាពលរដ្ឋគ្រប់រូបត្រូវចូលរួមថែរក្សាការពារ អភិរក្ស និង ត្រូវចូលរួមដាំដើមត្នោតនៅលើដីកម្មសិទ្ធិរបស់ខ្លួន។

៧-កម្មសិទ្ធិករដើមត្នោត ត្រូវបានរក្សាសិទ្ធិក្នុងការប្រើប្រាស់ដើមត្នោត និង ផលិតផលពីដើមត្នោតរបស់ខ្លួនប្រកបដោយនិរន្តរភាព។

៨-ត្រូវបានអនុញ្ញាតឱ្យមានការកែច្នៃជាលក្ខណៈប្រពៃណីនូវគ្រឿងចម្លាក់ សម្ភារៈប្រើប្រាស់វត្ថុអនុស្សាវរីយ៍ ដែលធ្វើពីឈើត្នោតប្រកបដោយការសន្សំសំចៃខ្ពស់ និងផលិតផលត្នោតកែច្នៃផ្សេងទៀត សម្រាប់បម្រើទីផ្សារក្នុងស្រុក ឬក្រៅស្រុក ដើម្បីបង្កើនមុខរបរជូនប្រជាពលរដ្ឋដោយមានការអនុញ្ញាត ពីសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៩-ហាមឃាត់ដាច់ខាតចំពោះអាជីវករទាំងឡាយណាដែលបំផុស និង ជំរុញចលនាកាប់ដើមត្នោតជាលក្ខណៈប្រមូលផ្តុំ ដើម្បីធ្វើការប្រមូលទិញ ការដឹកជញ្ជូន ការធ្វើសន្និធិក្នុងគោលបំណងពាណិជ្ជកម្ម ឬ ការបង្កើតរោងចក្រ រោងសិប្បកម្មកែច្នៃដើមត្នោត ឈើត្នោតជាលក្ខណៈឧស្សាហកម្ម ឬ ក្នុងគោលបំណងនាំចេញដើមត្នោត ឬ ឈើត្នោត។

១០-អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែន ត្រូវហាមឃាត់ដាច់ខាតការនាំចេញដើមត្នោតឈើត្នោតទៅក្រៅប្រទេស ។

១១-ការនាំចេញសំណាកដើមត្នោត ឈើត្នោតកែច្នៃ ផលិតផលត្នោតក្នុងគោលបំណងសិក្សាស្រាវជ្រាវ តាំងពិព័រណ៍ ឬ ដើម្បីប្រយោជន៍សាធារណៈផ្សេងទៀត ត្រូវសម្រេចដោយរាជរដ្ឋាភិបាល ។

១២-អាជីវករទាំងឡាយណាដែលប្រព្រឹត្តល្មើសចំពោះការហាមឃាត់ក្នុងបទបញ្ជានេះ នឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ទទួលបានបទបញ្ជានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងមហាផ្ទៃ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ចាត់ចែងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៧៨ សហវ.

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារ សម្រាប់កិច្ចប្រជុំ «ច្រកចេញ - ចូលតែមួយ» និង កិច្ចប្រជុំយន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង
- អនុក្រឹត្យលេខ ៧៨ អនក្រ. បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង ការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** បង្កើតក្រុមការងារសម្រាប់កិច្ចប្រជុំ «ច្រកចេញ- ចូលតែមួយ» និង កិច្ចប្រជុំយន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១. ឯកឧត្តម **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោក **អ៊ុយ សារិន** | តំណាងទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៤. លោក **ស្រី ទណ្ណា** | តំណាងនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥. លោក **ប៊ុន បុណ្ណារិទ្ធ** | តំណាងនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៦. លោក **សេង នួច** | តំណាងនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | សមាជិក |
| ៧. លោក **ខួន មាស** | ជំនួយការអគ្គលេខាធិការ | លេខាធិការ |
| ៨. លោក **ម៉ៅ បុរាណ** | ជំនួយការអគ្គលេខាធិការរង | លេខាធិការ |

**ប្រការ ២:** ក្រុមការងារនេះ មានភារកិច្ចដូចតទៅ:

- ពិនិត្យរាល់ឯកសារពាក់ព័ន្ធការងាររបស់អង្គប្រជុំ «ច្រកចេញ- ចូលតែមួយ» និង អង្គប្រជុំប្រហាក់ប្រហែលតាមការចាំបាច់ និង ការងារដែលត្រូវបំពេញ ដើម្បីដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សម្រេច ។
- តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមការងារចាត់ចែង និង ស្នើសុំយោបល់ចូលរួមប្រជុំរបស់ «ច្រកចេញ- ចូលតែមួយ» និង កិច្ចប្រជុំប្រហាក់ប្រហែល ផ្អែកលើតម្រូវការរបស់ក្រុមការងារ និង តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- ផ្តល់អនុសាសន៍ស្តីពីតម្រូវការជាក់ស្តែង និង ការងារជឿនលឿនថ្មីៗ ពាក់ព័ន្ធកិច្ចប្រជុំ «ច្រកចេញ- ចូលតែមួយ» និង អង្គប្រជុំប្រហាក់ប្រហែល ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សម្រេច ។
- ផ្តួចផ្តើមគំនិតរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងភារកិច្ច ដើម្បីធានាប្រសិទ្ធភាពក្រុមការងារ ក៏ដូចជារបស់ក្រសួង ។
- ធ្វើរបាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពីលទ្ធផលការងារ ដែលសម្រេចបានមួយឆមាសម្តង ។

**ប្រការ ៣:** ប្រធានក្រុមការងារនេះ ទទួលខុសត្រូវដឹកនាំការងាររួមរបស់ក្រុមការងារ ។ តាមការចាត់តាំង ឬ ក្នុងករណី

ប្រធានអវត្តមាន អនុប្រធានអចិន្ត្រៃយ៍ដឹកនាំការងារជំនួស ។ សមាសភាពក្រុមការងារត្រូវចូលរួមប្រជុំ តាមការអញ្ជើញ ក្នុងករណីអវត្តមាន អាចចាត់តំណាងរបស់ខ្លួនចូលរួមប្រជុំជំនួស ។ តំណាងដែលត្រូវបានចាត់ឱ្យចូលរួមជំនួស ត្រូវមានជំនាញពាក់ព័ន្ធការងារប្រជុំរបស់ «ច្រកចេញ- ចូលតែមួយ» និង មានសិទ្ធសម្រេចក្នុងនាមនាយកដ្ឋាន- អង្គភាពរបស់ខ្លួន ។ ក្រុមការងារ អាចអញ្ជើញមន្ត្រីពាក់ព័ន្ធនឹងការងាររបស់ខ្លួន ឱ្យចូលរួមប្រជុំបានតាមតម្រូវការជាក់ស្តែង ។

**ប្រការ ៤:** សមាសភាពក្រុមការងារ ដែលបានចូលរួមក្នុងកិច្ចប្រជុំនានា ដែលពាក់ព័ន្ធការងារ «ច្រកចេញ- ចូលតែមួយ» នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ កិច្ចប្រជុំប្រហាក់ប្រហែល ត្រូវរាយការណ៍ជូនក្រុមការងារពីលទ្ធផលនៃកិច្ចប្រជុំនោះ សម្រាប់ជាព័ត៌មាន និង ការតាមដាន សម្រាប់អង្គប្រជុំថ្ងៃមុខទៀត ។

**ប្រការ ៥:** លេខាធិការនៃក្រុមការងារ ត្រូវចូលរួមក្នុងកិច្ចប្រជុំ «ច្រកចេញ- ចូលតែមួយ» នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំ និង ស្រាវជ្រាវរកគ្រប់ឯកសារពាក់ព័ន្ធកិច្ចប្រជុំជូនក្រុមការងារឱ្យបានទៀងទាត់ ។

**ប្រការ ៦:** ប្រកាស ឬ សេចក្តីសម្រេច ដែលមានលក្ខណៈផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**គាត ឈន់**

***កន្លែងទទួល:***
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
  *«ដើម្បីជូនជ្រាប»*
- *ដូចប្រការ ៧*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៨១ សហវ.ប្រក.២០០៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

# ប្រកាសអន្តរក្រសួង
# ស្តីពី
# អាករបំណ្ណការងារ សៀវភៅការងារ និង កាតសេវាពិនិត្យសុខភាព

************

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និង
## រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជសរកម ០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- អនុវត្តតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យ ហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យ សាធារណៈ
- បានឃើញប្រកាសរួមលេខ ៥៦ សកបយ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីអាករប័ណ្ណការងារ និង សៀវភៅ ការងារ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរជ្ជទេយ្យចំណូល
- អនុវត្តតាមសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា
- បានឃើញមតិយល់ព្រមរបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦ លើលិខិតលេខ ៦៩៥ សហវ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញការចាំបាច់របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## សំរេច

**ប្រការ ១ :** អនុញ្ញាតឱ្យយកអាករលើប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ចំពោះកម្មករ និយោជិតជនជាតិខ្មែរ និង ជនបរទេស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** អាករលើប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវបានកំណត់ដូចខាងក្រោម:

ក- អាករលើប័ណ្ណការងារ និងសៀវភៅការងារ ចំពោះ កម្មករ និយោជិតជនជាតិខ្មែរម្នាក់ៗ ត្រូវកំណត់ តំលៃ ២ ៥០០ (ពីរពាន់ប្រាំរយ) រៀល ។ អាករនេះ ត្រូវបានកំណត់ឱ្យបង់ម្តងគត់ នៃអាជីពការងារ ។

ខ- អាករលើប័ណ្ណការងារ និង សៀវភៅការងារជនបរទេស ត្រូវបង់ប្រចាំឆ្នាំ:

- អាករប្រចាំឆ្នាំប្រតិទិន នៃប័ណ្ណការងារ និង សៀវភៅការងារជនបរទេសម្នាក់ៗ ដែលចូលមកស្នាក់នៅមានរយៈពេលកំណត់មួយច្បាស់លាស់ ដើម្បីប្រកបមុខរបរអ្វីមួយ ឬ ធ្វើអ្វីមួយយកប្រាក់ឈ្នួល ត្រូវបានកំណត់តំលៃ ១០០ (មួយរយ) ដុល្លារអាមេរិក ក្នុងប័ណ្ណការងារ និង សៀវភៅការងារមួយ ។
- អាករប្រចាំឆ្នាំប្រតិទិន នៃប័ណ្ណការងារ និង សៀវភៅការងារជនបរទេសម្នាក់ៗ ដែលមករស់នៅអចិន្ត្រៃយ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ ត្រូវបានកំណត់តំលៃ ៥០ (ហាសិប) ដុល្លារអាមេរិក ក្នុងប័ណ្ណការងារ និង សៀវភៅការងារមួយ ។

គ- ចំពោះជនបរទេស ដែលមានប័ណ្ណការងារ និង សៀវភៅការងាររួចហើយ ត្រូវមានកាតព្វកិច្ចដាក់ពាក្យស្នើសុំពន្យារទិដ្ឋាការ អោយបានមុនដំណាច់ខែមីនា ជារៀងរាល់ឆ្នាំ ។

ឃ- ចំពោះកំរៃសេវាលើការពិនិត្យសុខភាព ដែលនិយោជកត្រូវបង់ ត្រូវបានកំណត់ ដូចខាងក្រោម:

- ចំពោះកម្មករ និយោជិតជនជាតិខ្មែរម្នាក់ៗ ត្រូវបានកំណត់ចំនួន ១២ ០០០ (ដប់ពីរពាន់) រៀល ។
- ចំពោះជនបរទេសម្នាក់ៗ ត្រូវបានកំណត់ចំនួន ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក ។

ង- កម្មករ និយោជិតជនជាតិខ្មែរ និង ជនបរទេស ដែលបានបង់អាករប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវបានទទួលបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយនាយកដ្ឋានជំនាញ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុវត្តតាមច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

**ប្រការ ៣ :** កម្មករ និយោជិតជនជាតិខ្មែរ និង ជនបរទេស ប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនបានបង់អាករប័ណ្ណការងារ និង សៀវភៅការងារ ត្រូវផ្តន្ទាទោសទៅតាមច្បាប់ការងារ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤ :** ការបង់ប្រាក់ និង ការទទួលប្រាក់ចំណូលពីអាករប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវអនុវត្តតាមរយៈរជ្ជទេយ្យករចំណូល ឬរជ្ជទេយ្យករចំណូលរងនៅក្រសួង និង នៅមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ។

**ប្រការ ៥ :** ក- ការគ្រប់គ្រងចំណូលពីអាករប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវអនុវត្តតាមនិតិវិធី នៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ២១ ប្រការ ០៣ កថាខ័ណ្ឌ ៣០ សំរាប់ឆ្នាំ ២០០៦ និងកត់ត្រាក្នុងជំពូក គណនី អនុគណនី តាមមាតិកាថវិកាថ្មីដែលនឹងកែប្រែទៅតាមកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

ខ- ចំណូល ដែលប្រមូលបានដោយ ក្រសួង និង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង រជ្ជទេយ្យករចំណូល ត្រូវបង់ដោយត្រង់ចូលក្នុងគណនីរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង នៅធនាគារជាតិ ឬ សាខាធនាគារខេត្ត-ក្រុង ។

គ- ក្រសួង និង មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ត្រូវបូកសរុបធ្វើរបាយការណ៍ ចំណូលពីអាករប័ណ្ណការងារ សៀវភៅការងារ និងកំរៃសេវាពិនិត្យសុខភាពប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

**ប្រការ ៦ :** ក- ចំណូលពីអាករប័ណ្ណការងារ និង សៀវភៅការងារ ត្រូវបង់ ១០០% ចូលថវិការដ្ឋ ។ ក្នុងនោះ ៧០% ជាអត្ថប្រយោជន៍ថវិកាជាតិ និង អនុញ្ញាតឱ្យក្រសួង និងមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ដកវិញចំនួន៣០% សំរាប់ឧបត្ថម្ភដល់មន្ត្រីក្រោមឱវាទ ជាការលើកទឹកចិត្ត ក្នុងការបំពេញភារកិច្ចប្រមូលចំណូលនេះ ។

- ការដកចំណែក ៣០% របស់ក្រសួង និងមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ត្រូវធ្វើតាមរយៈអាណត្តិបើកប្រាក់ ដោយមានភ្ជាប់មកជាមួយ នូវរបាយការណ៍បូកសរុបចំណូល និងសលាកប័ត្រចំណូលថវិកាជាតិ ហើយកត់ត្រានៅក្នុង ជំពូក ១០ ប្រការ ០២ កថាខ័ណ្ឌ ០៣ វាក្យខ័ណ្ឌ ០៧ សំរាប់ឆ្នាំ ២០០៦ និងកត់ត្រាក្នុងជំពូក គណនី អនុគណនី តាមមាតិកាថវិកាថ្មីដែលនឹងកែប្រែទៅតាមកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

- ការដកចំណែក ៣០% របស់ក្រសួង និងមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ត្រូវចាប់អនុវត្តពីឆ្នាំ ២០០៦ តទៅ ។

ខ- ដោយឡែកចំណូលពីកំរៃសេវាពិនិត្យសុខភាព ត្រូវបានកំណត់ :

- ៥៣% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច
- ៤៥% សំរាប់ចំណាយឧបត្ថម្ភមន្ត្រីរាជការ និយោជិត
- ២% សំរាប់បង់ចូលថវិកាជាតិ ។

**ប្រការ ៧ :** - ការបោះពុម្ព ប័ណ្ណការងារ សៀវភៅការងារ វិញ្ញាបនប័ត្រពិនិត្យសុខភាព និង ប័ណ្ណចំណូល ត្រូវស្ថិតក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់គណៈកម្មការអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។

- ប័ណ្ណការងារ សៀវភៅការងារ វិញ្ញាបនប័ត្រពិនិត្យសុខភាព និង ប័ណ្ណចំណូល ត្រូវមានលេខរៀងត្រឹមត្រូវ និង មានលក្ខណៈសំគាល់ដោយឡែក រវាងកម្មករ និយោជិតជនជាតិខ្មែរ និង ជនបរទេស ដើម្បីងាយស្រួល គ្រប់គ្រង ។

**ប្រការ ៨ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

**ប្រការ ១០ :** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

**វ៉ង សូត**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធិសភា និង អធិការកិច្ច
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០០១៧ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

# សេចក្តីណែនាំ

## ស្តីពីការចូលរួមប្រជុំ «ច្រកចេញ - ចូលតែមួយ» និង យន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា

ដើម្បីធានាបាននូវប្រសិទ្ធភាព និង ការងាររលូនរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា និងផ្អែកតាមតម្រូវការជាក់ស្តែង កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាត់បញ្ជូនតំណាងរបស់ខ្លួនចូលរួមប្រជុំ និង សម្រេចបង្កើតក្រុមការងារ ដើម្បីពិនិត្យឯកសារពាក់ព័ន្ធនឹងកិច្ចប្រជុំ «ច្រកចេញ- ចូលតែមួយ» និង កិច្ចប្រជុំប្រហាក់ប្រហែល ដាក់ជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច ។ ជារួម យើងបានទទួលលទ្ធផលគួរជាទីពេញចិត្ត ។

ទន្ទឹមនឹងនេះ ដើម្បីឱ្យកិច្ចសហការនេះកាន់តែមានភាពរលូន និងកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដកិច្ច និង ហិរញ្ញវត្ថុ បានកត់សម្គាល់ឃើញថា នៅមានចំណុចមួយចំនួនត្រូវកែសម្រួល ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមណែនាំមន្ត្រីក្រោមឱវាទដូចខាងក្រោមនេះ:

**១ . កិច្ចប្រជុំច្រកចេញ - ចូលតែមួយ:**

- ការពិនិត្យផ្តល់គោលការណ៍វិនិយោគ និង ផ្តល់ការលើកទឹកចិត្តពន្ធ និង អាករ ការសម្រេចរបស់តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្អែកតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន

- ករណីក្រោយពីការលើកឡើង និងពិភាក្សា ប្រធានអង្គប្រជុំបានសម្រេចក្នុងលក្ខណៈផ្សេងពីមតិរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានលើកឡើង ជាពិសេសការងារពាក់ព័ន្ធការផ្តល់ការលើកទឹកចិត្ត និង ពន្ធ អាករ ជាដើម ដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងចូលរួមប្រជុំត្រូវសំណូមពរឱ្យមានការកត់ត្រាមតិទាំងនោះបញ្ចូលក្នុងរបាយការណ៍អង្គប្រជុំ ដែលត្រូវដាក់ជូនសម្តេចប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពិនិត្យ និងសម្រេច ។ ក្នុងករណី ដែលសំណូមពរនេះ មិនទទួលបាននូវការយល់ព្រមតំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនមកទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ទាក់ទងដល់សិទ្ធិប្រទាន និងកាលបរិច្ឆេទចុះហត្ថលេខាលើឯកសារនានា ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាហត្ថលេខី តំណាងចូលរួមប្រជុំ ត្រូវសុំឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា សហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និង សម្រេច ឬ សុំការសម្រេចពីសម្តេចនាយករដ្ឋមន្ត្រី

- ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យឯកសារពាក់ព័ន្ធ សម្រាប់ការចូលរួមប្រជុំ «ច្រកចេញ- ចូលតែមួយ» ក៏ដូចជាប្រជុំប្រហាក់ប្រហែល តំណាងចូលរួមប្រជុំត្រូវស្នើសុំឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ផ្ញើឯកសារពាក់ព័ន្ធសម្រាប់ការប្រជុំនេះ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មកដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃយ៉ាងតិច គិតចាប់ពីថ្ងៃដែលបានទទួល

- ចំពោះករណី ដែលបានទៅចូលប្រជុំជាធម្មតា ព្រមជាមួយនោះ អាចមានករណីស្នើដាក់បញ្ចូលរបៀបវារៈអង្គប្រជុំបន្ថែម តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីអង្គប្រជុំ ដើម្បីមានពេលវេលាគ្រប់គ្រាន់ សម្រាប់ពិនិត្យ និង ប្រមូលព័ត៌មានពាក់ព័ន្ធជាមូលដ្ឋានក្នុងការចូលរួមប្រជុំ ។

**២ . កិច្ចប្រជុំយន្តការអន្តរស្ថាប័ន:**

- ការចូលរួមពិនិត្យសំណើសុំអនុគ្រោះពន្ធនៃយន្តការអន្តរស្ថាប័ន ត្រូវផ្អែកលើមូលដ្ឋានឯកសារមានលក្ខណៈច្បាស់លាស់ និងគ្រប់គ្រាន់ និង ត្រូវបានទទួលដោយអង្គភាពពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងតិច ២ ថ្ងៃ នៃថ្ងៃធ្វើការ មុនកិច្ចដំណើការរបស់អង្គប្រជុំ

- មូលដ្ឋានក្នុងការពិនិត្យ និង សម្រេចលើសំណើសុំនីមួយៗ ត្រូវផ្អែកលើខ្លឹមសារ ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ។ ករណីមានសំណើសុំអនុគ្រោះពន្ធពីគម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមិនមានចែង ឬមានចែង ប៉ុន្តែ មិនមានខ្លឹមសារច្បាស់លាស់ក្នុងលិខិតបទដ្ឋាននានា តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសុំការសម្រេចជាមុនពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ក្រោយកិច្ចប្រជុំនីមួយៗ តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានកំណត់ហេតុ ឬ របាយការណ៍ ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាឱ្យបានច្បាស់លាស់ និង ទាន់ពេលវេលា ដើម្បីរក្សាទុកជាឯកសារផ្លូវការ

- រាល់របៀបវារៈបន្ថែម ដែលបានប្រគល់ឯកសារនៅថ្ងៃប្រជុំ តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើសុំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យ និង សម្រេច ។

ក្នុងករណី ដែលពុំមានការឯកភាពគ្នាជាធ្លុងមួយ ឬ ជួបប្រទះនូវភាពមិនប្រក្រតីនៅក្នុងអង្គប្រជុំ តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ ដើម្បីសុំការសម្រេចពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តមអគ្គលេខាធិការ នាយកខុទ្ទកាល័យ ទីចាត់គយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ ព្រមទាំងនាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពត៌មាន
MINISTRY OF INFORMATION
លេខ........ព.ម

រាជធានីភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ........

# ប្រកាស
# ស្ដីពីការបង្កើត ការិយាល័យពត៌មានវិទ្យា

## រដ្ឋមន្ត្រី ក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.ន.ស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
